ឬមួយក៏តិចជាង ចំនួនដែលបង្ហាញសម្រាប់ទំហំ នៃគ្រួសារលោកអ្នក នៅក្នុងតារាងប្រាក់ចំណូល ដែលផ្ទាប់មកជាមួយគ្នានេះ មជ្ឈមណ្ឌលថែទាំកូនក្មេងនោះ និងទទួល បានប្រាក់កម្រៃច្រើនថែមទៀត សម្រាប់ចំណីអាហារ ដែលយកទៅចិញ្ចឹមកូនលោកអ្នកនោះ ។

បទបញ្ជាតម្រូវឱ្យលោកអ្នក រាយការប្រាប់យើងខ្ញុំ ឱ្យបានដឹង ប្រសិនបើប្រាក់ចំណូលលោកអ្នក កើនឡើងក្នុងអម្លុងឆ្នាំនេះ ។ ការចុះថយ នៅក្នុងទំហំគ្រួសារ ឬ ការកើនប្រាក់ចំណូល ដែលលើសពី ៥០ ដុល្លារ ក្នុងមួយខែ ឬ លើសពី ៦០០ ដុល្លារ ក្នុង១ឆ្នាំ ចាំបាច់ត្រូវតែរាយការឱ្យដឹង ។ ប្រសិនលោកអ្នកផ្តល់ភស្តុតាង បង្ហាញនូវការ ទទួលបានប្រាក់កម្រៃ ហើយ រាយការអំពីប្រាក់ FOOD STAMP ប្រាក់ជំនួយជាបណ្តោះអាសន្ន សម្រាប់គ្រួសារខ្វះខាត(TANF) ឬលេខកម្មវិធី (Case number)ចែកចាយម្ហូបអាហារ នៅកន្លែងរស់នៅសម្រាប់ ជនជាតិ INDIAN ស្បែកក្រហមនោះ លោកអ្នកចាំបាច់ត្រូវតែ ប្រាប់ឱ្យយើងខ្ញុំបានដឹងដែរថា តើនៅពេលណាដែល លោកអ្នកឈប់ទទួល ប្រាក់កម្រៃទាំងនោះ ។ លោកអ្នកគួរតែប្រាប់ឱ្យយើងខ្ញុំដឹងផងដែរ ប្រសិនបើលោកអ្នកគ្មានការងារធ្វើ ហើយការបាត់បង់ប្រាក់ចំណូល ក្នុងអម្លុងពេលគ្មានការងារធ្វើនេះ ទាំឱ្យប្រាក់ចំណូល ក្នុងគ្រួសារលោកអ្នក ធ្លាក់ចុះ ដល់កំរិតអាចទទួលបានប្រាក់កម្រៃនោះ ។

<u>កូនចិញ្ចឹម</u>:

ចំពោះគ្រួសារដែលមានកូនចិញ្ចឹម សូមមើលអនុទ្ទេស ស្តីពីវិធីបំពេញសំណុំពាក្យសុំកម្រៃម្ហូបអាហារ(Meal Benefit Form) ឬមួយក៏សូមទាក់ទង ជាមួយយើងខ្ញុំ ដើម្បីទទួលពត៌មាន បន្ថែមទៀត ។

<u>ការរក្សាទុកជារៀងសម្ងាត់ នូវពត៌មានក្នុងសំណុំពាក្យសុំប្រាក់កម្រៃម្ហូបអាហារ</u>:

យើងខ្ញុំនិងប្រើប្រាស់ពត៌មាន នៅក្នុងសំណុំពាក្យនេះ ដើម្បីសម្រេចនូវ ចំនួនប្រាក់កម្រៃ ដែលអ្នកថែទាំកូនលោកអ្នកតាមផ្ទះ ឬ មជ្ឈមណ្ឌលថែទាំកូនក្មេង មានសិទ្ធអាចទទួលបាននោះ ។ យើងប្រហែលជាអាច ប្រាប់មន្ត្រីឯទៀត ខាងជីវជាតិម្ហូបអាហារកូនក្មេង ខាងសុខភាព និងខាងវិស័យសិក្សាអប់រំ នូវពត៌មាន នៅលើពាក្យរបស់លោកអ្នក ដើម្បីសម្រេចអំពី ផលកម្រៃសម្រាប់ កម្មវិធីទាំងនោះ ។